## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អង្គភាពអនុវត្តគម្រោងពិពិធកម្មកសិកម្មកម្ពុជា

# របាយការណ៍កិច្ចប្រជុំ
## គណៈកម្មការវាយតម្លៃ នៃគម្រោងពិពិធកម្មកសិកម្មកម្ពុជា

### ១. កម្មវត្ថុនៃកិច្ចប្រជុំ

នៅថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០២១, គណៈកម្មការវាយតម្លៃ (Evaluation Committee-EC) នៃគម្រោងពិពិធកម្មកសិកម្មកម្ពុជា (Cambodia Agricultural Sector Diversification Project-CASDP) បានបើកកិច្ចប្រជុំពិនិត្យ, វាយតម្លៃ និងដាក់ពិន្ទុ លើសំណើពិពិធកម្មនិងធុរកិច្ចរបស់ "**សហគមន៍កសិកម្មក្រាំងដីវ៉ាយ** (DPr២៩)" និងផែនការពិពិធកម្មនិងធុរកិច្ចរបស់ "**សហគមន៍កសិកម្មអញ្ចាញរូងសម័យថ្មី** (DPI៦)" មុននឹងបញ្ជូនទៅកាន់គណៈកម្មការប្រឹក្សាយោបល់និងអនុម័ត (AEC) ដើម្បីពិនិត្យ និងអនុម័តជាផ្លូវការ ដើម្បីអនុញ្ញាតឱ្យសហគមន៍កសិកម្មក្រាំងដីវ៉ាយ រៀបចំផែនការពិពិធកម្មនិងធុរកិច្ចបន្តទៀត និងសហគមន៍កសិកម្មអញ្ចាញរូងសម័យថ្មី ទទួលបានការគាំទ្រហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ។

### ២. សមាសភាពអង្គប្រជុំ

កិច្ចប្រជុំត្រូវបានដឹកនាំដោយ **លោក ឡៅ ប៉ូលីវេត** អនុប្រធាននាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ និងជាប្រធានគណៈកម្មការវាយតម្លៃ (EC) ដោយមានការចូលរួមពីសមាជិក និងសមាជិកា នៃគណៈកម្មការចំនួន ០៧ រូប រួមមាន÷ ១. លោក **ហុក គីមធួន**, ២. លោក **ឆេង វិបុលរិទ្ធ**, ៣. លោក **ទិត្យ សុជា**, ៤. លោក **សុខ បូរ៉ែន**, ៥. លោកស្រី **ជា សុខអ៊ីម** ៦.លោក **ដុក លួន** និង ៧. លោកស្រី **ហ៊ីង លីហួង** (តំណាងឱ្យលោក សុខ វឿន)។

### ៣. សេចក្តីសង្ខេបពីសំណើ និងផែនការពិពិធកម្ម និងធុរកិច្ច

#### <u>១. សំណើពិពិធកម្មនិងធុរកិច្ច</u>

**សហគមន៍កសិកម្មក្រាំងដីវ៉ាយ** មានទីតាំងស្ថិតនៅ ភូមិក្រសាំងខ្ពស់ ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ សហគមន៍ និងក្រុមផលិតចំនួន១ ក្រុម បានចូលរួមដាក់សំណើពង្រីកទំហំផលិតកម្មមាន់សាច់ពូជក្នុងស្រុក ដែលមានសមាជិកចូលរួមសរុប ៤៥ គ្រួសារ ស្ត្រី ១៤ នាក់។ សហគមន៍បានចុះបញ្ជីទទួលស្គាល់ជាផ្លូវការ ដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺ លេខៈ ១៧៩ មកខ/ក.ស ក្រោមវិញ្ញាបនប័ត្រលេខ ០០៥/សអក-កស/ ថ្ងៃ ១០ ខែមីនា ឆ្នាំ ២០១០។ សហគមន៍មានមុខរបរចម្បងៗដែលកំពុងដំណើរការសព្វថ្ងៃរួមមាន÷ ផ្តល់ទុនកម្ចីសម្រាប់ប្រកបមុខរបរកសិកម្ម(ដាំដុះបន្លែ

ចិញ្ចឹមមាន់ស្រែ ចិញ្ចឹមគោ ជ្រូក ផលិតកម្មស្រូវ) អាជីវកម្មខ្នាតតូច ព្រមទាំង សហគមន៍ ជួយសម្របសម្រួល ក្នុងការស្វែងរកទីផ្សារលក់កសិផលជូនសមាជិក។

ក្រោយពីទទួលបានព័ត៌មានពីគម្រោងពិពិធកម្មកសិកម្មកម្ពុជា (CASDP), សហគមន៍កសិកម្មក្រាំងដីវ៉ាយ បានរៀបចំសំណើពិពិធកម្មនិងធុរកិច្ចដែលមានតម្រូវការទឹកប្រាក់សរុបចំនួន ៤០១ ៥១១,៤០ ដុល្លារអាមេរិក ដោយផ្តោតលើការ **"ពង្រីកទំហំផលិតកម្មមាន់សាច់ពូជក្នុងស្រុក"** ដាក់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាណិជ្ជកម្មធ្វើការពិនិត្យពិចារណា និងគាំទ្រហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ។

គោលដៅរួមនៃសំណើពិពិធកម្មនិងធុរកិច្ចរបស់សហគមន៍កសិកម្មក្រាំងដីវ៉ាយគឺ៖ ពង្រីកទំហំផលិតកម្មមាន់សាច់សុវត្ថិភាពពូជក្នុងស្រុកជាមធ្យមចំនួន ៩០តោន/ឆ្នាំ ដើម្បីបង្កើនប្រាក់ចំណេញសុទ្ធដល់សមាជិកក្រុមផលិតជាមធ្យមជាង ១៦ ម៉ឺនដុល្លារអាមេរិក/ឆ្នាំ និងសហគមន៍អភិវឌ្ឍន៍កសិកម្មក្រាំងដីវ៉ាយជាមធ្យមជាង ៥៦ ០០០ ដុល្លារអាមេរិក/ឆ្នាំ តាមរយៈការពង្រីកទំហំចិញ្ចឹមមាន់សាច់ ការរៀបចំផែនការវិនិយោគច្បាស់លាស់ ការអនុវត្តន៍តាមបច្ចេកទេសថ្មីៗ ការប្រមូលផ្តុំទិញ និងលក់តាមការបញ្ជាទិញ ការកែលម្អខ្សែច្រវាក់ផលិតកម្មប្រកបដោយគុណភាពល្អ និងតាមស្តង់ដារសុវត្ថិភាព ក្នុងនោះមានប្រភពថវិកាដូចខាងក្រោម៖

**<u>ថវិកាសម្រាប់សហគមន៍</u>**

- ហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគពីគម្រោង CASDP សរុប ២១ ០៤៩,៦០ ដុល្លារអាមេរិក
- កម្ចីពីធនាគារឯកជនដែលសហការជាមួយគម្រោង CASDP សរុប ៣៨ ៧០៤ ដុល្លារអាមេរិក
- ទុនបដិភាគពីសហគមន៍ សរុប ១០ ៣៤៦,៤០ ដុល្លារអាមេរិក

ដូច្នេះ ថវិកាវិនិយោគរបស់សហគមន៍ គ្រោងទឹកប្រាក់សរុបចំនួន ៧០ ១០០ ដុល្លារអាមេរិក។

**<u>ថវិកាសម្រាប់ក្រុមផលិត</u>**

- ហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគពីគម្រោង CASDP សរុប ៩២ ១៩៨ ដុល្លារអាមេរិក
- កម្ចីពីធនាគារឯកជនដែលសហការជាមួយគម្រោង CASDP សរុប ១៤០ ៧២៤,៥៤ ដុល្លារអាមេរិក
- ទុនបដិភាគពីក្រុមផលិត សរុប ៩៨ ៤៨៨,៨៦ ដុល្លារអាមេរិក

ដូច្នេះ ថវិកាវិនិយោគរបស់ក្រុមផលិត គ្រោងទឹកប្រាក់សរុបចំនួន ៣៣១ ៤១១,៤០ ដុល្លារអាមេរិក។

## <u>២. ផែនការពិពិធកម្មនិងធុរកិច្ច</u>

**សហគមន៍កសិកម្មអញ្ចាញរូងសម័យថ្មី** មានទីតាំងស្ថិតនៅភូមិអណ្តូងរវៀង ឃុំអញ្ចាញរូង ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ដែលមានសមាជិកក្នុងក្រុមផលិតសរុប ៤០ គ្រួសារ។ សហគមន៍ បានចុះបញ្ជីទទួលស្គាល់ជាផ្លូវការដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ឆ្នាំង តាមរយៈលិខិតចុះបញ្ជីលេខ ០៣២/ស.គ.ក.សក/កជ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ ២០១៤។

សំណើពិពិធកម្មនិងធុរកិច្ចរបស់សហគមន៍កសិកម្មអញ្ចាញរូងសម័យថ្មី ត្រូវបានវាយតម្លៃដោយគណៈកម្មការវាយតម្លៃ នាថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០២១ និងអនុម័តដោយគណៈកម្មការប្រឹក្សាយោបល់និងអនុម័ត នាថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០២១ ដោយទទួលបានពិន្ទុ **៧១,៨០** ដើម្បីបន្តរៀបចំផែនការពិពិធកម្មនិងធុរកិច្ច។ តាមរយៈលទ្ធផលនៃការវាយតម្លៃនេះ សហគមន៍កសិកម្មអញ្ចាញរូងសម័យថ្មី បានបន្តរៀបចំផែនការពិពិធកម្មនិងធុរកិច្ចរបស់ខ្លួនដែលមានតម្រូវការថវិកាសរុបចំនួន **១៤៧ ៧៥៤**

ដុល្លារអាមេរិក ដោយផ្តោតលើការ"ពង្រីកផលិតកម្មមាន់សាច់ពូជក្នុងស្រុក ដើម្បីផ្គត់ផ្គង់តម្រូវការទីផ្សារ" ដើម្បីដាក់ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធធ្វើការពិនិត្យ ពិចារណា និងគាំទ្រហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ។

**<u>គោលដៅរួមគឺ</u>÷** ធ្វើឱ្យប្រសើរឡើងនូវទីផ្សារមាន់សាច់ពូជក្នុងស្រុក តាមរយៈការកែលម្អផលិតកម្ម និងគុណភាពនៃការចិញ្ចឹម ផលិតកម្មកូនមាន់ពូជ និងប្រមូលទិញស៊ុតមាន់ ដើម្បីផ្គត់ផ្គង់ទីផ្សារប្រើប្រាស់ និងភ្ញាស់កូនមាន់ ទទួលបានប្រាក់ចំណូលដុលចំនួនជាង ១ ១៦២ ៦៥០ ដុល្លារអាមេរិក ដែលនឹងត្រូវអនុវត្ត ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ ២០២២ រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២៤ ក្នុងរយៈពេល (៣ ឆ្នាំ) រួមមាន÷

១. កែលម្អ និងពង្រីកទំហំផលិតកម្មមាន់សាច់សុវត្ថិភាព ពូជក្នុងស្រុក ដើម្បីផ្គត់ផ្គង់តម្រូវការទីផ្សារក្នុងបរិមាណសរុប ១៨០ តោន ដែលទទួលបានប្រាក់ចំណូលដុល ៧៨៥ ៤០០ ដុល្លារអាមេរិក ក្នុងរយៈពេល ៣ ឆ្នាំ។

២. បង្កើនផលិតកម្មគុណភាពកូនមាន់ពូជ ប្រកបដោយគុណភាព តាមរយៈការជ្រើសរើសពូជមេបា បង្កើនភាពស៊ាំដោយវ៉ាក់សាំង ដែលសហគមន៍កសិកម្មគ្រោងសម្រេចបានផលិតកម្ម ចំនួនកូនមាន់ពូជចំនួន ១០១ ៥០១ ក្បាល ដែលស្មើ ១២៦ ៨៧៦ ដុល្លារអាមេរិក ក្នុងរយៈពេល ៣ ឆ្នាំ។

៣. ពង្រីកផលិតកម្មទីផ្សារស៊ុតមាន់ពូជក្នុងស្រុក ដោយសម្របសម្រួលទីផ្សារប្រមូលផ្តុំពីសមាជិកក្រុមផលិត ដើម្បីផ្គត់ផ្គង់ទីផ្សារចំនួន ៣៨៨ ៨០០ គ្រាប់ ដែលទទួលបានចំណូលដុលស្មើ ៩៧ ២០០ ដុល្លារអាមេរិក ក្នុងរយៈពេល ៣ ឆ្នាំ។

ក្នុងនោះ មានប្រភពថវិកាដូចខាងក្រោម÷

**<u>ថវិកាសម្រាប់សហគមន៍</u>**

- ហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគពីគម្រោង CASDP សរុប ៤ ៤៨៨ ដុល្លារអាមេរិក
- ទុនបដិភាគពីសហគមន៍ សរុប ១៥ ១៩៥ ដុល្លារអាមេរិក

ដូច្នេះ ថវិកាវិនិយោគរបស់សហគមន៍ គ្រោងទឹកប្រាក់សរុបចំនួន ១៩ ៦៨៣ ដុល្លារអាមេរិក។

**<u>ថវិកាសម្រាប់ក្រុមផលិត</u>**

- ហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគពីគម្រោង CASDP សរុប ៣២ ៦៣០,៨៤ ដុល្លារអាមេរិក
- កម្ចីពីធនាគារឯកជនដែលសហការជាមួយគម្រោង CASDP សរុប ៤៤ ៤៩៦,៦០ ដុល្លារអាមេរិក
- ទុនបដិភាគពីក្រុមផលិត សរុប ៥០ ៩៤៣,៥៦ ដុល្លារអាមេរិក

ដូច្នេះ ថវិកាវិនិយោគរបស់ក្រុមផលិត គ្រោងទឹកប្រាក់សរុបចំនួន ១២៨ ០៧១ ដុល្លារអាមេរិក។

**<u>ចំពោះ ការគាំទ្រហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សហគមន៍បានស្នើសុំ÷</u>**

(១). ប្រព័ន្ធធារាសាស្ត្រក្រៅកសិដ្ឋាន - មិនមានស្នើសុំទេ។

(២). ផ្លូវលំជនបទ - ជួសជុលកែលម្អផ្លូវចំនួន ០២ ខ្សែ ប្រវែងសរុប ៩ ៧០០ ម៉ែត្រ÷

- **ខ្សែទី ០១**÷ មានប្រវែង ៥ ៧០០ ម៉ែត្រ ទទឹងផ្លូវ ៧ ម៉ែត្រ (កៅស៊ូពីរជាន់) ជាប្រភេទផ្លូវក្រាលគ្រួសក្រហម ទទឹងផ្លូវចាស់ ៥ ម៉ែត្រ ស្មាផ្លូវ ១ ម៉ែត្រសងខាង។ ក្រុមបច្ចេកទេសគ្រោងកែលម្អផ្លូវនេះជាប្រភេទផ្លូវកៅស៊ូពីរជាន់ DBST-

Type ២ ទទឹងកៅស៊ូ ៥ ម៉ែត្រ ស្មាផ្លូវ ១ ម៉ែត្រសងខាងសរុបទទឹងផ្លូវ ៧ ម៉ែត្រ ដោយសារផ្លូវនេះមានគ្រឹះរឹងមាំស្រាប់ អាចពង្រីកបាន ដោយពុំមានផលប៉ះពាល់អ្វីទេ ហើយម្យ៉ាងទៀតផ្លូវនេះតភ្ជាប់ពីផ្លូវកៅស៊ូទៅផ្លូវកៅស៊ូ ឆ្ពោះទៅផ្លូវជាតិលេខ ៥ ដែលអាចបង្កើតជាបណ្ដាញផ្លូវដ៏ល្អក្នុងសហគមន៍។ ផ្លូវនេះបម្រើឱ្យសមាជិកសហគមន៍ចំនួន ១០៥ គ្រួសារ ក្នុងការដឹកកសិផលរបស់ពួកគាត់មកទីតាំងសហគមន៍ ឬ ទៅកាន់ផ្សារ ពន្លៃយ៉ាងងាយស្រួល។

- **ខ្សែទី ០២÷** មានប្រវែង ៤ ០០០ ម៉ែត្រ ទទឹងផ្លូវ ៧ ម៉ែត្រ(កៅស៊ូពីរជាន់) ជាប្រភេទផ្លូវលំក្រាលគ្រួសក្រហមមានទទឹង ៥ ម៉ែត្រ ស្មាផ្លូវ ០,៥ ម៉េត្រសងខាង)។ ក្រុមបច្ចេកទេសគ្រោងកែលម្អផ្លូវនេះជាប្រភេទផ្លូវកៅស៊ូពីរជាន់ DBST-Type ២ ទទឹងកៅស៊ូ ៥ ម៉ែត្រ ស្មាផ្លូវ ១ ម៉ែត្រសងខាងសរុបទទឹងផ្លូវ ៧ ម៉ែត្រ ដោយសារផ្លូវនេះមានគ្រឹះរឹងមាំស្រាប់ អាចពង្រីកបាន ដោយពុំមានផលប៉ះពាល់អ្វីទេ ហើយម្យ៉ាងទៀតផ្លូវនេះតភ្ជាប់ពីផ្លូវកៅស៊ូទៅផ្លូវកៅស៊ូឆ្ពោះទៅផ្លូវជាតិលេខ ៥ ដែលអាចបង្កើតជាបណ្ដាញផ្លូវដ៏ល្អក្នុងសហគមន៍។ ផ្លូវនេះបម្រើឱ្យសមាជិកសហគមន៍ចំនួន ១៣៣ គ្រួសារ ក្នុងការដឹកកសិផលរបស់ពួកគាត់មកទីតាំងសហគមន៍ ឬ ទៅកាន់ផ្សារ ពន្លៃយ៉ាងងាយស្រួល ។

តាមរយៈការចុះសិក្សាលម្អិត តម្រូវការថវិកាប៉ាន់ស្មានសម្រាប់ជួសជុលកែលម្អផ្លូវចំនួន ០២ ខ្សែ នេះ សរុបចំនួន **១ ៥៥២ ០០០ ដុល្លារអាមេរិក។**

## ៤. នីតិវិធីនៃការវាយតម្លៃ និងដាក់ពិន្ទុ លើសំណើ និងផែនការពិពិធកម្ម

ការដាក់ពិន្ទុលើសំណើ (DPr) និងផែនការពិពិធកម្មនិងធុរកិច្ច (DPI) ត្រូវបានធ្វើឡើងដោយសមាជិកគណៈកម្មការ EC ម្នាក់ៗ និងផ្អែកលើលក្ខណៈវិនិច្ឆ័យចំនួន ៧ ចំណុច រួមមាន÷ ១) ភាពពាក់ព័ន្ធរបស់ DPr/DPI ជាមួយក្របខ័ណ្ឌគម្រោង, ២) បទពិសោធន៍របស់តួអង្គពាក់ព័ន្ធក្នុងការប្រកបអាជីវកម្ម, ៣) ការរៀបចំ DPr/BPr និង DPI/BPI, ៤) ឧបសគ្គ និងហានិភ័យដែលនឹងត្រូវធ្វើការឆ្លើយតប, ៥) ការវិភាគហិរញ្ញវត្ថុ, ៦) ផលជះផ្នែកបរិស្ថាន និង ៧) ផលជះផ្នែកសង្គមរបស់គម្រោង។ ទន្ទឹមនេះ សមាជិកម្នាក់ធ្វើការដាក់ពិន្ទុលើសំណើ និងផែនការ ចន្លោះពី ១ ទៅ ១០០ ពិន្ទុ លើសំណើ និងផែនការពិពិធកម្មនិងធុរកិច្ច ម្តងមួយៗ (ពិន្ទុដែលផ្តល់ដោយសមាជិកម្នាក់ៗ នៃគណៈកម្មការវាយតម្លៃ មិនត្រូវបានអនុញ្ញាតឱ្យចែករំលែកដល់សមាជិកគណៈកម្មការដ៏ទៃទៀតដឹងនោះឡើយ)។ សំណើ និងផែនការពិពិធកម្មនិងធុរកិច្ចមួយដែលត្រូវបានវាយតម្លៃដោយសមាជិកគណៈកម្មការ EC ចំនួន ៨ រូប គឺអាចមានពិន្ទុអតិបរមាត្រឹមតែ ៨០០ ពិន្ទុ ប៉ុណ្ណោះ។

## ៥. លទ្ធផលនៃការវាយតម្លៃ និងដាក់ពិន្ទុ

តាមរយៈការធ្វើមធ្យមភាគនៃពិន្ទុវាយតម្លៃរបស់សមាជិកគណៈកម្មការ EC ម្នាក់ៗ លើសំណើពិពិធកម្មនិងធុរកិច្ចរបស់ **“សហគមន៍កសិកម្មក្រាំងជីវ៉ាយ”** បានបង្ហាញឱ្យឃើញថា សហគមន៍ទទួលបានពិន្ទុសរុប **៧១,៤០** លើពិន្ទុសរុប ១០០។ ចំណែកឯ ផែនការពិពិធកម្មនិងធុរកិច្ចរបស់ **“សហគមន៍កសិកម្មអញ្ចាញរូងសម័យថ្មី”** ទទួលបានពិន្ទុសរុប **៧១,៩០** លើពិន្ទុសរុប ១០០។

ការវាយតម្លៃតាមលក្ខណៈវិនិច្ឆ័យរបស់សមាជិកគណៈកម្មការ EC ម្នាក់ៗ មានខ្លឹមសារលម្អិតក្នុងតារាងខាងក្រោម÷

# គណៈកម្មការវាយតម្លៃ "សំណើពិពិធកម្មនិងធុរកិច្ចរបស់ សហគមន៍កសិកម្មក្រាំងដីវ៉ាយ "

| ល.រ | ចំណុចត្រូវវាយតម្លៃ | ពិន្ទុអតិបរមា | ពិន្ទុផ្តល់ដោយសមាជិក | | | | | | | | | សេចក្តីពន្យល់ពីការដាក់ពិន្ទុ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | EC1 | EC2 | EC3 | EC4 | EC5 | EC6 | EC7 | EC8 | Average Score | |
| **១. ភាពពាក់ព័ន្ធនៃDPI ជាមួយក្របខ័ណ្ឌគម្រោង** | | | | | | | | | | | | |
| | ១.១. សនិទានភាព (ហេតុផល) និងគោលដៅ DPI គឺរៀបចំសរសេរបានល្អ<br>The rationale and objectives of the proposed DPI are well formulated | 5 | 4 | 4 | 4 | 4 | 4 | 4 | 4 | 4 | 4.0 | គួរឱ្យចាប់អារម្មណ៍ខ្លាំង (impressive) = ៥;<br>ល្អប្រសើរ (substantially)= ៤<br>ល្អ (good) = ៣;<br>ខ្លះៗ (Some) = ២,<br>ខ្សោយ (poor) = ១ |
| | ១.២. ភាពពាក់ព័ន្ធរបស់DPI នេះ នឹងជួយឱ្យសម្រេចគោលដៅគម្រោង CASDP<br>The relevance of the proposed DPI to reach the objective of the CASDP project | 5 | 4 | 4 | 4 | 4 | 4 | 3 | 3 | 3 | 3.6 | គួរឱ្យចាប់អារម្មណ៍ខ្លាំង (impressive) = ៥;<br>ល្អប្រសើរ (substantially) = ៤;<br>ល្អ (good) = ៣;<br>ខ្លះៗ (some) = ២,<br>ខ្សោយ (poor) = ១ |
| **២. បទពិសោធន៍របស់តួអង្គពាក់ព័ន្ធ** | | | | | | | | | | | | |
| | ២.១. ចំនួនឆ្នាំគិតជាមធ្យមនៃការប្រកបអាជីវកម្មរបស់ក្រុមផលិត និងកសិធុរកិច្ចខ្នាតតូច និងមធ្យម ដែលបានចុះបញ្ជី<br>Average year of legal constitution of POs and SMAs | 5 | 3 | 3 | 3 | 3 | 4 | 3 | 4 | 4 | 3.4 | លើសពី ៣ ឆ្នាំ = ៥;<br>ចន្លោះពី ២ ទៅ ៣ ឆ្នាំ = ៤;<br>ចន្លោះពី ១ ទៅ ២ ឆ្នាំ = ៣;<br>ចន្លោះពី 0,៥ ទៅ ១ ឆ្នាំ =២;<br>តិចជាង 0,៥ ឆ្នាំ = ១ |
| | ២.២. បទពិសោធន៍របស់ក្រុមផលិត ក្នុងការលក់ផលិតរបស់ខ្លួនរួមគ្នាជាក្រុម<br>Experience of PO to market their products together as a group | 5 | 3 | 3 | 3 | 3 | 4 | 3 | 3 | 4 | 3.3 | គួរឱ្យចាប់អារម្មណ៍ខ្លាំង = ៥;<br>ល្អប្រសើរ = ៤;<br>ល្អ = ៣;<br>ខ្លះៗ = ២,<br>ខ្សោយ = ១ |
| | ២.៣. BPI នីមួយៗ របស់ DPI មានភ្ជាប់មកជាមួយនូវ លិខិតបញ្ជាក់បំណងក្នុងការ ទិញទំនិញពីដៃគូអ្នកបញ្ជា ទិញ<br>Each BPI of the DPI is supported by a letter of intent of purchase by a potential buyer. | 5 | 4 | 4 | 5 | 5 | 5 | 5 | 5 | 4 | 4.6 | DPI មានលិខិតបញ្ជាក់បំណង ១00% = ៥;<br>DPI មានលិខិតបញ្ជាក់បំណងលើសពី៥0% = ៤<br>DPI មានលិខិតបញ្ជាក់បំណង ៥0%=៣<br>DPI មានលិខិតបញ្ជាក់បំណងតិចជាង ៥0%=២<br>DPI ពុំមានលិខិតបញ្ជាក់បំណង 0%=១ |
| **៣. ការរៀបចំDPI/ BPI** | | | | | | | | | | | | |
| | ៣.១. ការជ្រើសរើសការ វិនិយោគដែលមានផលិតភាពនៅក្នុង BPI របស់ក្រុមផលិត និងកសិធុរកិច្ចខ្នាតតូច និងមធ្យមគឺត្រឹមត្រូវ និងសម ស្រប ដែលនឹងអាចសម្រេច បានទៅតាមគោលដៅ របស់ DPI និង BPI ហើយនិងគោលដៅអភិវឌ្ឍន៍របស់គម្រោង<br>(Productive investment in BPI for POs and SMAs are well chosen to achieve the objective of the DPI and BPI and the development objective of the Project.) | 10 | 6 | 8 | 8 | 8 | 6 | 8 | 8 | 6 | 7.3 | ទាំងស្រុង (Totally) = ១0;<br>បង្គួរ (substantially) = ៨;<br>ភាគច្រើន (mostly) = ៦;<br>ល្មមគ្រប់គ្រាន់ (just enough) = ៤;<br>មិនគ្រប់គ្រាន់ (not enough) = ២ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ៣.២. ផែនការ BPI នៅក្នុង DPI គឺមានដាក់បញ្ចូលនូវ ដំណើរការ ក្នុងកម្រិតកសិដ្ឋាន, ប្រមូលផ្តុំ, កែច្នៃ និងទីផ្សារ ដែលមានលក្ខណៈពាណិជ្ជកម្ម ដោយប្រើប្រាស់បច្ចេកវិទ្យា ដែលមានលក្ខណៈនវានុវត្តន៍<br>BPI in DPI include/s innovative technological and commercial processes at farm, aggregation, processing and marketing level. | 5 | 3 | 4 | 4 | 4 | 4 | 3 | 4 | 4 | 3.8 | ទាំងស្រុង (Totally) = ៥;<br>បង្គួរ (substantially) = ៤;<br>ភាគច្រើន (mostly) = ៣;<br>ល្មមគ្រប់គ្រាន់ (just enough) = ២;<br>មិនគ្រប់គ្រាន់ (not enough) = ១ |
| ៣.៣. ផែនការ BPI នៅក្នុង DPI មានការដាក់បញ្ចូលនូវការបន្ថែមតម្លៃដល់ផលិតផល កសិកម្មបឋម តាមរយៈការធ្វើ បម្លាស់ប្រែ ឬការកែច្នៃ ការជ្រើសរើស និងការធ្វើ ចំណាត់ថ្នាក់ផលិតផល តាមរយៈការវេចខ្ចប់ និងដាក់ស្លាក សម្គាល់ ជាដើម<br>BPI in DPI propose/s adding value to primary production through transformation/processing, or through product sorting and selection by physical traits and/or packing, packaging and/or labelling. | 5 | 4 | 4 | 3 | 3 | 4 | 4 | 3 | 3 | 3.5 | ទាំងស្រុង (Totally) = ៥;<br>បង្គួរ (substantially)= ៤;<br>ភាគច្រើន (mostly)= ៣;<br>ល្មមគ្រប់គ្រាន់ (just enough)= ២;<br>មិនគ្រប់គ្រាន់ (not enough)= ១ |
| ៣.៤. ផែនការវិនិយោគលើ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ត្រូវបានជ្រើសរើសយ៉ាងត្រឹមត្រូវ ដើម្បីគាំទ្រដល់ការ សម្រេចគោលបំណង DPI និងគោលបំណងអភិវឌ្ឍន៍របស់គម្រោង ហើយថវិកា ដែលស្មើឡើងមានលក្ខណៈសមស្រប<br>Supporting public investments are well chosen to support achieving the objective of the DPI and the development objective of the Project, and are within acceptable budget | 5 | 4 | 3 | 4 | 4 | 3 | 4 | 3 | 3 | 3.5 | **ក. ការវាយតម្លៃដាក់ពិន្ទុប្រសិនបើសហគមន៍បានស្នើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ**<br>ទាំងស្រុង (Totally)= ៥<br>បង្គួរ (substantially)= ៤;<br>ភាគច្រើន (mostly)= ៣;<br>**ខ. ការវាយតម្លៃដាក់ពន្ទុប្រសិនបើសហគមន៍បានស្នើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ**<br>ពិន្ទុផ្តល់ឱ្យ÷ ៣ |
| ៣.៥. BPI នៅក្នុង DPI មាន អំណះអំណាងច្បាស់លាស់ដែលបញ្ជាក់ថា តម្រូវការទីផ្សារសម្រាប់ផលិតផល/ សេវាកម្ម ដែលបានស្នើឡើង កំពុងមានការកើនឡើង<br>The BPI under the DPI is/are supported by evidence that the targeted market for proposed products/services is growing. | 5 | 4 | 4 | 4 | 4 | 4 | 4 | 4 | 4 | 4.0 | ទាំងស្រុង (Totally) = ៥;<br>បង្គួរ (substantially)= ៤;<br>ភាគច្រើន (mostly) = ៣;<br>ល្មមគ្រប់គ្រាន់ (just enough)= ២;<br>មិនគ្រប់គ្រាន់ (not enough) = ១ |
| ៣.៦. BPI នៅក្នុង DPI បានដាក់បញ្ចូលនូវការអនុវត្តកសិកម្មល្អ (GAP) និងការអនុវត្តល្អក្នុងកម្រិតរោងចក្រ/ សហគ្រាស/ សិប្បកម្ម/ កន្លែងកែច្នៃផលិតផលកសិកម្ម (GMP)<br>BPI under DPI explicitly incorporate good agricultural practices and good manufacturing practices | 5 | 3 | 3 | 3 | 3 | 5 | 3 | 3 | 3 | 3.3 | ទាំងពីរ (Both) = ៥;<br>មួយក្នុងចំណោមទាំងពីរ (One of them) = ៣;<br>មិនមានណាមួយ (none)=១ |
| **៤. ឧបសគ្គ និងហានិភ័យ ដែលនឹងត្រូវធ្វើការឆ្លើយតប** | | | | | | | | | | | |
| តើមានការរៀបរាប់អំពីហានិភ័យ ដែលសហគមន៍/ ក្រុមផលិត/ កសិធុរកិច្ចខ្នាតតូច និងមធ្យម កំពុងជួបប្រទះនាពេលបច្ចុប្បន្ន និងវិធានការដើម្បីកាត់បន្ថយហានិភ័យទាំងនោះដែរឬទេ?<br>Are current risks and mitigation measures well formulated? | 5 | 4 | 3 | 4 | 3 | 4 | 3 | 3 | 4 | 3.5 | ទាំងស្រុង (Totally) = ៥;<br>បង្គួរ (substantially) = ៤;<br>ភាគច្រើន (mostly) = ៣;<br>ល្មមគ្រប់គ្រាន់ (just enough) = ២;<br>មិនគ្រប់គ្រាន់ (not enough) = ១ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| **៥. ការវិភាគហិរញ្ញវត្ថុ** | | | | | | | | | | | |
| លទ្ធភាពទទួលបានផលចំណេញជាមធ្យមសម្រាប់ការវិនិយោគដែលបានស្នើឡើង ដោយ PO និង SMA ដែលត្រូវបានបង្ហាញជាអត្រាផលចំណេញសុទ្ធ ដែលស្មើនឹង ផលចំណេញសុទ្ធ ធៀបនឹងចំណូលពីការលក់<br>(Net Margin = Net Profit/ Revenues) Average financial viability for proposed investment of POs and SMAs expressed in Net Margin (= Net Profit / Revenues) | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5.0 | ជាង ១0% (More than 10%) = ៥<br>រហូតដល់ ១0% (Up to 10%) = ៣<br>រហូតដល់ ៥% (Up to 5%) = ១ |
| **៦. ផលជះផ្នែកបរិស្ថាន** | | | | | | | | | | | |
| តើគម្រោងនេះផ្តល់ផលជះអ្វីខ្លះដល់បរិស្ថាន?<br>What is the impact of the project on the environment? | 5 | 3 | 3 | 4 | 3 | 4 | 4 | 4 | 4 | 3.6 | វិជ្ជមានខ្ពស់ (Very Positive) = ៥;<br>វិជ្ជមាន (Positive) = ៤;<br>វិជ្ជមានដែរ (rather positive) = ៣;<br>ធម្មតា (Neutral) = ២;<br>អវិជ្ជមាន(Negative)=១ |
| **៧. ផលជះផ្នែកសង្គមរបស់គម្រោង** | | | | | | | | | | | |
| ៧.១. តើបានបញ្ជាក់ច្បាស់លាស់ពីផលជះអវិជ្ជមានផ្នែកសង្គម ចេញពីគម្រោង ដែរឬទេ?<br>Are adverse social impacts identified | 5 | 3 | 3 | 3 | 3 | 3 | 3 | 3 | 3 | 3.0 | ទាំងស្រុង (Totally) =៥;<br>ភាគច្រើន (mostly)= ៣;<br>មិនគ្រប់គ្រាន់ (not sufficiently) = ១ |
| ៧.២. តើ DPI នេះបានបង្កើតការងារថ្មីៗដែរឬទេ? (ការងារអចិន្ត្រៃយ៍ និងការងារតាមរដូវកាល)<br>Does the DPI create new jobs (permanent and seasonal) | 5 | 2 | 3 | 2 | 3 | 2 | 2 | 3 | 3 | 2.5 | ជាង ២0 នាក់ = ៥;<br>ចន្លោះ ១0 និង ២0 នាក់ = ៤;<br>ចន្លោះ ៥ និង ១0 នាក់ = ៣;<br>ចន្លោះ ១ និង ៥ នាក់ = ២;<br>មិនមាននរណាម្នាក់ឡើយ (none) = ១ |
| ៧.៣. តើ DPI នេះ មានផែនការជាក់លាក់ដើម្បីធានាថាស្ត្រី យុវជន និងក្រុមងាយរងគ្រោះឯទៀតនឹងទទួលបានផលប្រយោជន៍ពីគម្រោង ដែរឬទេ?<br>Does the DPI has concrete plans how to make sure that women and youth and other vulnerable groups will benefit from the Project? | 5 | 4 | 3 | 2 | 3 | 4 | 3 | 3 | 4 | 3.3 | ទាំងស្រុង (Totally)= ៥;<br>បង្គួរ(substantially)= ៤<br>ភាគច្រើន (mostly)= ៣;<br>ល្មមគ្រប់គ្រាន់ (just enough)= ២;<br>មិនគ្រប់គ្រាន់ (not enough)=១ |
| ៧.៤. BPI និងផែនការច្រវាក់តម្លៃ ដែលបានជ្រើសរើស មានវិយិទ្ធភាពទៅនឹងអាហារូបត្ថម្ភ (Nutrition Sensitive) ឬទេ ហើយផែនការទាំងនោះ អាចត្រូវបាន កំណត់ថាជាផែនការដែលបានរួមចំណែកដល់ការកាត់បន្ថយបញ្ហានៃកង្វះអាហារូបត្ថម្ភ ក្នុងចំណោមប្រជាជនកម្ពុជាដែរឬទេ? Are the BPI and selected value chains nutrition-sensitive and can they be defined as those that can contribute to reducing undernutrition in the Cambodian population? | 5 | 3 | 3 | 4 | 4 | 3 | 4 | 4 | 3 | 3.5 | ទាំងស្រុង (Totally)= ៥;<br>បង្គួរ(substantially)= ៤<br>ភាគច្រើន (mostly)= ៣;<br>ល្មមគ្រប់គ្រាន់ (just enough) = ២;<br>មិនគ្រប់គ្រាន់ (not enough) =១ |
| ៧.៥. តើ BPI និងផែនការខ្សែច្រវាក់តម្លៃផ្តោតទៅលើការនាំចេញ ហើយផែនការទាំងនោះអាចត្រូវបានកំណត់ថាជាផែនការដែលអាចរួមចំណែកដល់ការជំរុញការនាំចេញផលិតផលកសិកម្មកម្ពុជា ដែរឬទេ?<br>Are the BPI and selected value chains export-oriented and can they be defined as those that can contribute to promoting Cambodia‟s exports of agricultural products? | 5 | 3 | 4 | 3 | 3 | 3 | 3 | 2 | 2 | 2.9 | ទាំងស្រុង (Totally)= ៥;<br>បង្គួរ(substantially)= ៤<br>ភាគច្រើន (mostly)= ៣;<br>ល្មមគ្រប់គ្រាន់ (just enough) = ២;<br>មិនគ្រប់គ្រាន់ (not enough) =១ |
| **Total Score** | **100** | **69** | **71** | **72** | **72** | **75** | **71** | **71** | **70** | **71.4** | |

# គណៈកម្មការវាយតម្លៃ "សំណើពិពិធកម្មនិងធុរកិច្ចរបស់ សហគមន៍កសិកម្មអញ្ជាញផ្លូវសម័យថ្មី"

| ល.រ | ចំណុចត្រូវវាយតម្លៃ | ពិន្ទុអតិបរមា | ពិន្ទុផ្តល់ដោយសមាជិក | | | | | | | | | សេចក្តីពន្យល់ពីការដាក់ពិន្ទុ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | EC1 | EC2 | EC3 | EC4 | EC5 | EC6 | EC7 | EC8 | Average Score | |
| **១. ភាពពាក់ព័ន្ធនៃ DPI ជាមួយក្របខ័ណ្ឌគម្រោង** | | | | | | | | | | | | |
| | ១.១. សនិទានភាព (ហេតុផល) និងគោលដៅ DPI គឺរៀបចំសរសេរបានល្អ<br>The rationale and objectives of the proposed DPI are well formulated | 5 | 4 | 3 | 4 | 4 | 4 | 4 | 4 | 4 | 3.9 | គួរឱ្យចាប់អារម្មណ៍ខ្លាំង (impressive) = ៥;<br>ល្អប្រសើរ (substantially)= ៤<br>ល្អ (good) = ៣;<br>ខ្លះៗ (Some) = ២,<br>ខ្សោយ (poor) = ១ |
| | ១.២. ភាពពាក់ព័ន្ធរបស់DPI នេះ នឹងជួយឱ្យសម្រេចគោលដៅគម្រោង CASDP<br>The relevance of the proposed DPI to reach the objective of the CASDP project | 5 | 4 | 4 | 4 | 4 | 4 | 4 | 3 | 4 | 3.9 | គួរឱ្យចាប់អារម្មណ៍ខ្លាំង (impressive) = ៥;<br>ល្អប្រសើរ (substantially) = ៤;<br>ល្អ (good) = ៣;<br>ខ្លះៗ (some) = ២,<br>ខ្សោយ (poor) = ១ |
| **២. បទពិសោធន៍របស់តួអង្គពាក់ព័ន្ធ** | | | | | | | | | | | | |
| | ២.១. ចំនួនឆ្នាំគិតជាមធ្យមនៃការប្រកបអាជីវកម្មរបស់ក្រុមផលិត និងកសិធុរកិច្ចខ្នាតតូច និងមធ្យម ដែលបានចុះបញ្ជី<br>Average year of legal constitution of POs and SMAs | 5 | 3 | 3 | 4 | 3 | 4 | 3 | 4 | 3 | 3.4 | លើសពី ៣ ឆ្នាំ = ៥;<br>ចន្លោះពី ២ ទៅ ៣ ឆ្នាំ = ៤;<br>ចន្លោះពី ១ ទៅ ២ ឆ្នាំ = ៣;<br>ចន្លោះពី ០,៥ ទៅ ១ ឆ្នាំ =២;<br>តិចជាង ០,៥ ឆ្នាំ = ១ |
| | ២.២. បទពិសោធន៍របស់ក្រុមផលិត ក្នុងការលក់ផលិតរបស់ខ្លួនរួមគ្នាជាក្រុម<br>Experience of PO to market their products together as a group | 5 | 3 | 3 | 3 | 3 | 4 | 4 | 3 | 4 | 3.4 | គួរឱ្យចាប់អារម្មណ៍ខ្លាំង = ៥;<br>ល្អប្រសើរ = ៤;<br>ល្អ = ៣;<br>ខ្លះៗ = ២,<br>ខ្សោយ = ១ |
| | ២.៣. BPI នីមួយៗ របស់ DPI មានភ្ជាប់មកជាមួយនូវ លិខិតបញ្ជាក់បំណងក្នុងការ ទិញទំនិញពីដៃគូអ្នកបញ្ជា ទិញ<br>Each BPI of the DPI is supported by a letter of intent of purchase by a potential buyer. | 5 | 4 | 4 | 4 | 4 | 4 | 4 | 4 | 5 | 4.1 | DPI មានលិខិតបញ្ជាក់បំណង ១០០% = ៥;<br>DPI មានលិខិតបញ្ជាក់បំណងលើសពី៥០% = ៤<br>DPI មានលិខិតបញ្ជាក់បំណង ៥០%=៣<br>DPI មានលិខិតបញ្ជាក់បំណងតិចជាង ៥០%=២<br>DPI ពុំមានលិខិតបញ្ជាក់បំណង ០%=១ |
| **៣. ការរៀបចំDPI/ BPI** | | | | | | | | | | | | |
| | ៣.១. ការជ្រើសរើសការ វិនិយោគដែលមានផលិតភាពនៅក្នុង BPI របស់ក្រុមផលិត និងកសិធុរកិច្ចខ្នាតតូច និងមធ្យមគឺត្រឹមត្រូវ និងសម ស្រប ដែលនឹងអាចសម្រេច បានទៅតាមគោលដៅ របស់ DPI និង BPI ហើយនិងគោលដៅអភិវឌ្ឍន៍របស់គម្រោង<br>(Productive investment in BPI for POs and SMAs are well chosen to achieve the objective of the DPI and BPI and the development objective of the Project.) | 10 | 6 | 8 | 8 | 8 | 6 | 8 | 6 | 6 | 7.0 | ទាំងស្រុង (Totally) = ១០;<br>បង្គួរ (substantially) = ៨;<br>ភាគច្រើន (mostly) = ៦;<br>ល្មមគ្រប់គ្រាន់ (just enough) = ៤;<br>មិនគ្រប់គ្រាន់ (not enough) = ២ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៣.២. ផែនការ BPI នៅក្នុង DPI គឺមានដាក់បញ្ចូលនូវ ដំណើរការ ក្នុងកម្រិតកសិដ្ឋាន, ប្រមូលផ្ដុំ, កែច្នៃ និងទីផ្សារ ដែលមានលក្ខណៈពាណិជ្ជកម្ម ដោយប្រើប្រាស់ បច្ចេកវិទ្យា ដែលមានលក្ខណៈនវានុវត្តន៍<br>BPI in DPI include/s innovative technological and commercial processes at farm, aggregation, processing and marketing level. | 5 | 4 | 4 | 4 | 3 | 4 | 4 | 4 | 3 | 3.8 | ទាំងស្រុង (Totally) = ៥;<br>បង្គួរ (substantially) = ៤;<br>ភាគច្រើន (mostly) = ៣;<br>ល្មមគ្រប់គ្រាន់ (just enough) = ២;<br>មិនគ្រប់គ្រាន់ (not enough) = ១ |
| ៣.៣. ផែនការ BPI នៅក្នុង DPI មានការដាក់បញ្ចូលនូវការបន្ថែមតម្លៃដល់ផលិតផល កសិកម្មបឋម តាមរយៈការធ្វើ បម្លាស់ប្រែ ឬការកែច្នៃ ការជ្រើសរើស និងការធ្វើ ចំណាត់ថ្នាក់ផលិតផល តាមរយៈការវេចខ្ចប់ និងដាក់ស្លាក សម្គាល់ ជាដើម<br>BPI in DPI propose/s adding value to primary production through transformation/processing, or through product sorting and selection by physical traits and/or packing, packaging and/or labelling. | 5 | 4 | 4 | 3 | 4 | 4 | 4 | 3 | 4 | 3.8 | ទាំងស្រុង (Totally) = ៥;<br>បង្គួរ (substantially)=៤;<br>ភាគច្រើន (mostly)=៣;<br>ល្មមគ្រប់គ្រាន់ (just enough)=២;<br>មិនគ្រប់គ្រាន់ (not enough)=១ |
| ៣.៤. ផែនការវិនិយោគលើ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ត្រូវបានជ្រើសរើសយ៉ាងត្រឹមត្រូវ ដើម្បីគាំទ្រដល់ការ សម្រេចគោលបំណង DPI និងគោលបំណងអភិវឌ្ឍន៍របស់គម្រោង ហើយថវិកា ដែលស្នើឡើងមានលក្ខណៈសមស្រប<br>Supporting public investments are well chosen to support achieving the objective of the DPI and the development objective of the Project, and are within acceptable budget | 5 | 4 | 3 | 4 | 5 | 4 | 4 | 3 | 4 | 3.9 | **ក. ការវាយតម្លៃដាក់ពិន្ទុប្រសិនបើសហគមន៍បានស្នើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ**<br>ទាំងស្រុង (Totally)= ៥<br>បង្គួរ (substantially)= ៤;<br>ភាគច្រើន (mostly)= ៣;<br>**ខ. ការវាយតម្លៃដាក់ពន្ទុប្រសិនបើសហគមន៍បានស្នើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ**<br>ពិន្ទុផ្តល់ឱ្យ÷ ៣ |
| ៣.៥. BPI នៅក្នុង DPI មាន អំណះអំណាងច្បាស់លាស់ដែលបញ្ជាក់ថា តម្រូវការទីផ្សារសម្រាប់ផលិតផល/ សេវាកម្ម ដែលបានស្នើឡើង កំពុងមានការកើនឡើង<br>The BPI under the DPI is/are supported by evidence that the targeted market for proposed products/services is growing. | 5 | 4 | 3 | 4 | 4 | 4 | 4 | 3 | 3 | 3.6 | ទាំងស្រុង (Totally) = ៥;<br>បង្គួរ (substantially)= ៤;<br>ភាគច្រើន (mostly) = ៣;<br>ល្មមគ្រប់គ្រាន់ (just enough)=២;<br>មិនគ្រប់គ្រាន់ (not enough) = ១ |
| ៣.៦. BPI នៅក្នុង DPI បានដាក់បញ្ចូលនូវការអនុវត្តកសិកម្មល្អ (GAP) និងការអនុវត្តល្អក្នុងកម្រិតរោងចក្រ/ សហគ្រាស/ សិប្បកម្ម/ កន្លែងកែច្នៃផលិតផលកសិកម្ម (GMP)<br>BPI under DPI explicitly incorporate good agricultural practices and good manufacturing practices | 5 | 3 | 3 | 3 | 3 | 3 | 3 | 3 | 3 | 3.0 | ទាំងពីរ (Both) = ៥;<br>មួយក្នុងចំណោមទាំងពីរ (One of them) = ៣;<br>មិនមានណាមួយ (none)=១ |
| **៤. ឧបសគ្គ និងហានិភ័យ ដែលនឹងត្រូវធ្វើការឆ្លើយតប** | | | | | | | | | | | |
| តើមានការរៀបរាប់អំពីហានិភ័យ ដែលសហគមន៍/ ក្រុមផលិត/ កសិធុរកិច្ចខ្នាតតូច និងមធ្យម កំពុងជួបប្រទះនាពេលបច្ចុប្បន្ន និងវិធានការដើម្បីកាត់បន្ថយហានិភ័យទាំងនោះដែរឬទេ?<br>Are current risks and mitigation measures well formulated? | 5 | 4 | 3 | 3 | 3 | 4 | 4 | 4 | 4 | 3.6 | ទាំងស្រុង (Totally) = ៥;<br>បង្គួរ (substantially) = ៤;<br>ភាគច្រើន (mostly) = ៣;<br>ល្មមគ្រប់គ្រាន់ (just enough) = ២;<br>មិនគ្រប់គ្រាន់ (not enough) = ១ |
| **៥. ការវិភាគហិរញ្ញវត្ថុ** | | | | | | | | | | | |
| លទ្ធភាពទទួលបានផលចំណេញជាមធ្យមសម្រាប់ការវិនិយោគដែលបានស្នើឡើងដោយ PO និង SMA ដែលត្រូវបានបង្ហាញជាអត្រាផលចំណេញសុទ្ធ ដែលស្មើនឹង ផលចំណេញសុទ្ធ ធៀបនឹងចំណូលពីការលក់<br>(Net Margin = Net Profit/ Revenues) Average financial viability for proposed investment of POs and SMAs expressed in Net Margin (= Net Profit / Revenues) | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5.0 | ជាង ១០% (More than 10%) = ៥<br>រហូតដល់ ១០% (Up to 10%) = ៣<br>រហូតដល់ ៥% (Up to 5%) = ១ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| **៦. ផលជះផ្នែកបរិស្ថាន** | | | | | | | | | | | |
| តើគម្រោងនេះផ្តល់ផលជះអ្វីខ្លះដល់បរិស្ថាន?<br>What is the impact of the project on the environment? | 5 | 4 | 3 | 4 | 4 | 4 | 4 | 4 | 4 | 3.9 | វិជ្ជមានខ្ពស់ (Very Positive) = ៥;<br>វិជ្ជមាន (Positive) = ៤;<br>វិជ្ជមានដែរ (rather positive) = ៣;<br>ធម្មតា (Neutral) = ២;<br>អវិជ្ជមាន(Negative)=១ |
| **៧. ផលជះផ្នែកសង្គមរបស់គម្រោង** | | | | | | | | | | | |
| ៧.១. តើបានបញ្ជាក់ច្បាស់លាស់ពីផលជះអវិជ្ជមានផ្នែកសង្គម ចេញពីគម្រោង ដែរឬទេ?<br>Are adverse social impacts identified | 5 | 3 | 3 | 3 | 3 | 5 | 3 | 3 | 3 | 3.3 | ទាំងស្រុង (Totally) =៥;<br>ភាគច្រើន (mostly)=៣;<br>មិនគ្រប់គ្រាន់ (not sufficiently) = ១ |
| ៧.២. តើ DPI នេះបានបង្កើតការងារថ្មីៗដែរឬទេ? (ការងារអចិន្ត្រៃយ៍ និងការងារតាមរដូវកាល)<br>Does the DPI create new jobs (permanent and seasonal) | 5 | 2 | 3 | 2 | 3 | 2 | 2 | 3 | 3 | 2.5 | ជាង ២០ នាក់ = ៥;<br>ចន្លោះ ១០ និង ២០ នាក់ = ៤;<br>ចន្លោះ ៥ និង ១០ នាក់ = ៣;<br>ចន្លោះ ១ និង ៥ នាក់ = ២;<br>មិនមាននរណាម្នាក់ឡើយ (none) = ១ |
| ៧.៣. តើ DPI នេះ មានផែនការជាក់លាក់ដើម្បីធានាថាស្ត្រី យុវជន និងក្រុមងាយរងគ្រោះឯទៀតនឹងទទួលបានផលប្រយោជន៍ពីគម្រោង ដែរឬទេ?<br>Does the DPI has concrete plans how to make sure that women and youth and other vulnerable groups will benefit from the Project? | 5 | 4 | 3 | 4 | 4 | 4 | 4 | 4 | 4 | 3.9 | ទាំងស្រុង (Totally)=៥;<br>បង្គួរ(substantially)=៤<br>ភាគច្រើន (mostly)=៣;<br>ល្មមគ្រប់គ្រាន់ (just enough)=២;<br>មិនគ្រប់គ្រាន់ (not enough)=១ |
| ៧.៤. BPI និងផែនការច្រវាក់តម្លៃ ដែលបានជ្រើសរើស មានវិយិទ្ធភាពទៅនឹងអាហារូបត្ថម្ភ (Nutrition Sensitive) ឬទេ ហើយផែនការទាំងនោះ អាចត្រូវបានកំណត់ថាជាផែនការដែលបានរួមចំណែកដល់ការកាត់បន្ថយបញ្ហានៃកង្វះអាហារូបត្ថម្ភ ក្នុងចំណោមប្រជាជនកម្ពុជាដែរឬទេ? Are the BPI and selected value chains nutrition-sensitive and can they be defined as those that can contribute to reducing undernutrition in the Cambodian population? | 5 | 4 | 4 | 4 | 4 | 3 | 3 | 4 | 3 | 3.6 | ទាំងស្រុង (Totally)=៥;<br>បង្គួរ(substantially)=៤<br>ភាគច្រើន (mostly)=៣;<br>ល្មមគ្រប់គ្រាន់ (just enough) =២;<br>មិនគ្រប់គ្រាន់ (not enough) =១ |
| ៧.៥. តើ BPI និងផែនការខ្សែច្រវាក់តម្លៃផ្តោតទៅលើការនាំចេញ ហើយផែនការទាំងនោះអាចត្រូវបានកំណត់ថាជាផែនការដែលអាចរួមចំណែកដល់ការជំរុញការនាំចេញផលិតផលកសិកម្មកម្ពុជា ដែរឬទេ?<br>Are the BPI and selected value chains export-oriented and can they be defined as those that can contribute to promoting Cambodia‟s exports of agricultural products? | 5 | 2 | 3 | 3 | 3 | 3 | 2 | 2 | 2 | 2.5 | ទាំងស្រុង (Totally)=៥;<br>បង្គួរ(substantially)=៤<br>ភាគច្រើន (mostly)=៣;<br>ល្មមគ្រប់គ្រាន់ (just enough) =២;<br>មិនគ្រប់គ្រាន់ (not enough) =១ |
| **Total Score** | 100 | 71 | 69 | 73 | 74 | 75 | 73 | 69 | 71 | 71.9 | |

## ៦. សេចក្តីសន្និដ្ឋានរបស់គណៈកម្មការវាយតម្លៃ

យោងតាមលទ្ធផលនៃការវាយតម្លៃ និងដាក់ពិន្ទុរបស់គណៈកម្មការEC លើសំណើពិពិធកម្មនិងធុរកិច្ចរបស់ **"សហគមន៍កសិកម្មក្រាំងជីវ៉ាយ"** ដែលទទួលបានពិន្ទុចំនួន **៧១,៤០** គឺមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការបន្តរៀបចំផែនការពិពិធកម្មនិងធុរកិច្ចលម្អិត។ អាស្រ័យហេតុនេះ សមាជិកគណៈកម្មការ EC ទាំងអស់បានសម្រេច និងឯកភាពបញ្ជូនលទ្ធផលនេះ ជូនទៅគណៈកម្មការប្រឹក្សាយោបល់ និងអនុម័ត(AEC) ធ្វើការពិនិត្យ និងសម្រេចជាផ្លូវការលើលទ្ធផលនៃវាយតម្លៃនេះ ដើម្បីផ្តល់លទ្ធភាពឱ្យ សហគមន៍កសិកម្ម អាចរៀបចំផែនការពិពិធកម្មនិងធុរកិច្ចបន្ត។

ជាមួយគ្នានេះ គណៈកម្មការបានស្នើឱ្យសហគមន៍កសិកម្មក្រាំងជីវ៉ាយ ត្រូវរៀបរាប់ឱ្យច្បាស់លាស់នូវព័ត៌មានមួយចំនួននៅក្នុងផែនការពិពិធកម្មនិងធុរកិច្ច ដូចខាងក្រោម÷

- ពិនិត្យឡើងវិញលើការវិភាគហិរញ្ញវត្ថុកម្រិតសហគមន៍ ដែលអត្រាចំណេញសុទ្ធទទួលបានរហូតដល់ ៩៦% (ការប្រមូលផ្តុំមាន់សាច់ និងភ្ញាស់កូនមាន់)។ តើពិតជាត្រឹមត្រូវដែរឬទេ?
- ពិនិត្យមើលឡើងវិញនូវ ការរៀបចំផែនការថវិកាសម្រាប់ចំណាយ ត្រូវលម្អិតឱ្យបានច្បាស់លាស់។
- បញ្ជាក់លម្អិត តាមមុខងារចំណាយ និង Specification នីមួយៗក្នុង ១ ឯកតា។
- ការចំណាយ លើការកាត់វិលស់ ការសាងសង់អាគារជាកន្លែងប្រមូលផ្តុំ, ចាក់សាប, សំណាញ់ដែក, ....។ល។ គួរដាក់រួមគ្នា ១ កញ្ចប់ ក្រោមចំណងជើង "ការកាត់វិលស់លើ......"។ ផ្តល់ព័ត៌មានលម្អិតពីការកាត់វិលស់ (ទាំងកម្រិតសហគមន៍ និងក្រុមផលិត)។
- ផ្តល់ព័ត៌មានពីការបង្កើតការងារ។

ចំណែកឯ លទ្ធផលនៃការវាយតម្លៃ និងដាក់ពិន្ទុ លើផែនការពិពិធកម្មនិងធុរកិច្ចរបស់ **"សហគមន៍កសិកម្មអញ្ចាញរូងសម័យថ្មី"** ទទួលបានពិន្ទុ **៧១,៩០** គឺមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានការគាំទ្រហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគពីគម្រោងទៅតាមការស្នើសុំ ស្របទៅតាមគោលការណ៍ Matching Grant Facility Guidelines។ អាស្រ័យហេតុនេះ សមាជិកគណៈកម្មការEC ទាំងអស់បានសម្រេច និងឯកភាពបញ្ជូនលទ្ធផលនេះ ជូនទៅគណៈកម្មការប្រឹក្សាយោបល់ និងអនុម័ត(AEC) ធ្វើការពិនិត្យ និងសម្រេចជាផ្លូវការលើលទ្ធផលនៃការវាយតម្លៃនេះ។ ទន្ទឹមនេះ គណៈកម្មការ EC ក៏បានស្នើសហគមន៍បញ្ជាក់ឱ្យបានច្បាស់លាស់ និងធ្វើការកែសម្រួលនូវចំណុចសំខាន់ៗមួយចំនួន ដើម្បីធ្វើឱ្យផែនការពិពិធកម្មនិងធុរកិច្ច មានព័ត៌មានគ្រប់ជ្រុងជ្រោយ។ ដូច្នេះ ក្រោយពេលគណៈកម្មការ AEC ធ្វើការសម្រេចអនុម័តលើផែនការពិពិធកម្មនិងធុរកិច្ចរួចរាល់, សហគមន៍កសិកម្មត្រូវធ្វើការសហការជាមួយអ្នកផ្តល់សេវាបច្ចេកទេស (TSP) ដើម្បីបំភ្លឺ និងកែសម្រួលលើចំណុចមួយចំនួនទៅតាមមតិយោបល់ដូចមានរៀបរាប់ខាងក្រោម មុននឹងបញ្ជូនផែនការពិពិធកម្មនិងធុរកិច្ចត្រលប់មកវិញ ដើម្បីផ្ទៀងផ្ទាត់ និងទទួលបានការអនុម័តពេញលេញ រួមមាន÷

- ការប្រមូលផ្តុំមាន់សាច់ ស៊ុតមាន់ និងផ្សាំកូនមាន់(កម្រិតសហគមន៍)÷ ពិនិត្យមើលឡើងវិញ និងកាត់បន្ថយនូវមុខងារចំណាយមួយចំនួន ដែលមិនមានតម្រូវការចាំបាច់ (ធ្វើឱ្យថ្លៃដើមកើនឡើង និងប្រាក់ចំណេញ

ថយចុះសម្រាប់សហគមន៍) ប្រសិនបើអាចធ្វើទៅបាន សហគមន៍ត្រូវពិនិត្យលទ្ធភាព ធ្វើយ៉ាងណាឱ្យប្រាក់ចំណេញលើស ៧%។

- ពិនិត្យមើលឡើងវិញនូវ ការរៀបចំផែនការថវិកាសម្រាប់ចំណាយ គួរលម្អិតឱ្យបានច្បាស់លាស់ ជាពិសេសការចំណាយ**វិនិយោគរបស់ក្រុមផលិត** ១.១ (សាងសង់រោងមាន់ ចាក់សាបព័ទ្ធសំណាញ់ដែក និងសំណាញ់អួន) នឹងការចំណាយ**វិនិយោគរបស់សហគមន៍កសិកម្ម** ១.១ (សាងសង់កន្លែងប្រមូលផ្តុំមាន់សាច់ ស៊ុតមាន់ និងផ្សាំកូនមាន់) ចំនួនប៉ុន្មាន សម្រាប់ប៉ុន្មានគ្រួសារ។
- ការចំណាយលើការកាត់រំលស់ ការសាងសង់រោងមាន់ ចាក់សាប ទូរភ្ញាស់ ....។ល។ គួរដាក់រួមគ្នា ១ កញ្ចប់ក្រោមចំណងជើង "ការកាត់រំលស់លើ......."។ ផ្តល់ព័ត៌មានលម្អិតពីការកាត់រំលស់ (ទាំងកម្រិតសហគមន៍ និងក្រុមផលិត)។
- បញ្ជាក់លម្អិត តាមមុខងារចំណាយ និង Specification នីមួយៗក្នុង ១ ឯកតា ដូចជា÷ ការចំណាយវិនិយោគរបស់ក្រុមផលិត ១.១ សាងសង់រោងមាន់ ចាក់សាបព័ទ្ធសំណាញ់ដែក និងសំណាញ់អួន តើមានប៉ុន្មានគ្រួសារដែលបានស្នើសុំ និងធ្វើការបូកសរុបផ្ទៀងផ្ទាត់ កែសម្រួលឡើងវិញ?
- បើអាចបង្កើនទំហំធុរកិច្ចបានធំជាងនេះកាន់តែប្រសើរ។
- ផ្តល់ព័ត៌មានពីការបង្កើតការងារ។

ជាកិច្ចបញ្ចប់ **លោក ឡៅ ប៉ូលីវេត** ប្រធានគណៈកម្មការ EC បានធ្វើការថ្លែងអំណរគុណដល់សមាជិកអង្គប្រជុំទាំងអស់ដែលបានចូលរួមកិច្ចប្រជុំនេះ និងស្នើសុំសមាជិកគណៈកម្មការ EC ចូលរួមកិច្ចប្រជុំបន្ទាប់ **នៅថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ២០២១** វេលាម៉ោង **០៩:០០ នាទីព្រឹក** ក្នុងគោលបំណងពិនិត្យ, វាយតម្លៃ និងដាក់ពិន្ទុលើសំណើពិពិធកម្មនិងធុរកិច្ចរបស់ "**សហគមន៍កសិកម្មពេលសាមគ្គីមានពន្លឺ** (DPr ៣០)" និង "**សហគមន៍កសិកម្មក្រាំងលាវសាមគ្គី** (DPr ៣១)"។ លោកប្រធាន បានប្រកាសបិទអង្គប្រជុំនៅថ្ងៃដដែល វេលាម៉ោង ១២:០០ នាទី ថ្ងៃត្រង់។

ថ្ងៃចន្ទ ១ រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០២១

**លេខាធិការ**
**នៃគណៈកម្មការវាយតម្លៃ**

**ធាន កុសល**

ថ្ងៃចន្ទ ១ រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០២១

**យោបល់**

បានឃើញ និងឯកភាព

**ប្រធានគណៈកម្មការវាយតម្លៃ**

**ឡៅ ប៉ូលីវេត**